ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ:..........✓..................

# សេចក្តីជូនដំណឹង
# ស្តីពី
# «ការប្រារព្ធទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស» លើកទី០៨ ឆ្នាំ២០២៤ ក្រោមប្រធានបទៈ «ការអប់រំសីលធម៌តាមវិស័យសាសនា បង្ការទប់ស្កាត់អំពើជួញដូរមនុស្សសម័យឌីជីថល»

អគ្គលេខាធិការដ្ឋាននៃ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) មានកិត្តិយស សូមគោរពប្រគេន ទូលថ្វាយ និងគោរពជម្រាបជូន ព្រះថេរានុត្ថេរៈ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី បណ្តាញសារព័ត៌មាន និងសាធារណជនទាំងអស់ មេត្តាជ្រាបថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងរៀបចំប្រារព្ធ **«ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស លើកទី៨ ឆ្នាំ២០២៤»** ក្រោមប្រធានបទៈ **«ការអប់រំសីលធម៌តាមវិស័យសាសនា បង្ការទប់ស្កាត់អំពើជួញដូរមនុស្សសម័យឌីជីថល»** នៅថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨ ត្រូវនឹង **ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ** រាជធានីភ្នំពេញ ចាប់ពីម៉ោង ៨ព្រឹកតទៅ។

**«ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស លើកទី៨ ឆ្នាំ២០២៤»** នេះ នឹងត្រូវប្រារព្ធឡើង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃ**ព្រះរាជាណាចក្រកម្ពុជា** ដោយមានការចូលរួមពីថ្នាក់ដឹកនាំក្នុងជួររាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា មេដឹកនាំសាសនា និងសាសនិកនៃ និកាយសាសនាធំៗទាំងបួន មន្ត្រីរាជការ យុវជន យុវនារី កងកម្លាំងគ្រប់ប្រភេទ និងអង្គការដៃគូជាតិ អន្តរជាតិ មានចំនួនសរុបប្រមាណ **២៥០០ អង្គ/នាក់**។ គោលបំណងសំខាន់ៗនៃការប្រារព្ធទិវាជាតិអន្តរសាសនាលើកនេះគឺដើម្បីៈ

*១-បញ្ជាក់ពីគោលជំហរ និងការប្តេជ្ញាចិត្តដ៏មុតមាំ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងនៅក្នុងប្រទេសកម្ពុជា កម្រិតតំបន់ និងកម្រិតអន្តរជាតិ។*

*២-បង្ហាញពីសុខដុមនីយកម្ម និងកិច្ចសហប្រតិបត្តិការជាធ្លុងមួយពីសំណាក់មេដឹកនាំ និងសាសនិក នៃសាសនានានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងបរិបទសង្គមប្រកបដោយសុខសន្តិភាព ចូលរួមអនុវត្តសកម្មភាពដើម្បីសម្រេចគោលបំណងរួម គឺបង្ការទប់ស្កាត់សំដៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់។*

*៣-បង្ហាញពីតួនាទីសំខាន់របស់សាសនា និងជំហរក្នុងការបន្តចូលរួម ពីសំណាក់មេដឹកនាំ និងសាសនិកពីគ្រប់និកាយសាសនា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។*

សេចក្តីដូចបានគោរពប្រគេន ទូលថ្វាយ និងគោរពជម្រាបជូនខាងលើ សូមព្រះថេរានុត្ថេរៈ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី បណ្តាញសារព័ត៌មាន និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១២កើត ខែ ស្រាពណ៍ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ សីហា ឆ្នាំ២០២៤

*សូមទំនាក់ទំនងលេខទូរស័ព្ទៈ*
០១១ ៨៨៥ ១២៣